មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក

**រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០២៤**

ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ ជាទិវាសេរីភាពសារព័ត៌មានពិភពលោក។ ទិវានេះប្រារព្ធឡើងដើម្បីគោរពដល់តួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មាន ក្នុងការនាំយកព័ត៌មានដែលត្រឹមត្រូវ និងអាចទុកចិត្តបានដល់សាធារណជន ពេលខ្លះពួកគេប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតរបស់ខ្លួន និងជាការរំលឹកអំពីសារៈសំខាន់នៃសេរីភាពសារព័ត៌មានក្នុងការលើកកម្ពស់សិទ្ធិមនុស្ស អភិបាលកិច្ចល្អ និងប្រជាធិបតេយ្យ។ ទិវានេះក៏ជាការរំលឹកដល់រដ្ឋាភិបាលនៅជុំវិញពិភពលោកឱ្យបង្កើននូវបរិយាកាសដែលសេរីភាពសារព័ត៌មានត្រូវបានផ្តល់នូវអំណាច និងការការពារ ដែលអាចឱ្យប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យបំពេញតួនាទីដ៏មានសារៈសំខាន់របស់ខ្លួនដោយសេរី មិនមានការបៀតបៀន ឬភ័យខ្លាចនូវការតបត។

ជាការគួរឱ្យសោកស្តាយ ម.ស.ម.ក សង្កេតឃើញថាប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យនៅកម្ពុជានៅតែបន្តប្រឈមនឹងឧបសគ្គជាច្រើននៅក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនដោយសេរី និងគ្មានការដាក់កំហិតសិទ្ធិរបស់ខ្លួនឯង។ ការបន្តដៅមុខសញ្ញាទៅលើប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិដែលជាសិទ្ធិមូលដ្ឋានរបស់ពួកគេនៅតែបន្តកើតមាននៅក្នុងសង្គមកម្ពុជា។

នៅចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ អ្នកសារព័ត៌មានច្រើនជាង ១៦នាក់រងយាយីតាមប្រព័ន្ធតុលាការដោយសារតែការរាយការណ៍ព័ត៌មានរបស់ខ្លួន និងអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន ៥ ត្រូវបានដកហូត។ នៅក្នុងសន្ទស្សន៍នៃសេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៣ បានវាយតម្លៃថាប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៤៧ ក្នុងចំណោមប្រទេសចំនួន ១៨០ ដែលបានបង្ហាញពីការធ្លាក់ចុះ បើប្រៀបធៀបជាមួយទិន្នន័យពីឆ្នាំមុនៗ។ រហូតមកដល់ពេលនេះ អាជ្ញាធរកម្ពុជានៅតែខកខានក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាពចំពោះករណីស្លាប់របស់អ្នកសារព័ត៌មានចំនួន ១៥ រូប ដែលត្រូវបានសម្លាប់ក្នុងអំឡុងពេលពីរទសវត្សចុងក្រោយនេះ ហើយជនល្មើសក៏មិនទាន់ត្រូវចាប់មកផ្តន្ទាទោសឱ្យស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិនៅឡើយ។

នៅក្នុងបរិបទនៃការបន្តធ្លាក់ចុះនៃបរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ទិវានេះកាន់តែមានសារៈសំខាន់ក្នុងការរំលឹកថា បើគ្មានប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យនោះទេ លទ្ធិប្រជាធិបតេយ្យក៏មិនអាចរីកចម្រើនផងដែរ។

ដើម្បីប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកនៅឆ្នាំនេះ ម.ស.ម.ក នឹងរៀបចំ យុទ្ធនាការនៅការិយាល័យ និងតាមអនឡាញដើម្បីផ្តល់ព័ត៌មានដល់សាធារណជនអំពីទិវានេះ និងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ និងតួនាទីរបស់អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅក្នុងសង្គមប្រជាធិបតេយ្យ។ សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់ព្រឹត្តិការណ៍ដូចខាងក្រោម៖

- នៅថ្ងៃទី៣០ ខែមេសា ម.ស.ម.ក នឹងចេញផ្សាយកម្រងសំណួរនៅលើប្រព័ន្ធអនឡាញស្តីពី សេរីភាពសារព័ត៌មាន សិទ្ធិទទួលព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ។
- ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១០ ខែឧសភា ម.ស.ម.ក នឹងផ្សព្វផ្សាយឡើងវិញនូវជីវប្រវត្តិរបស់អ្នកសារព័ត៌មាន១០រូប នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។
- នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») នឹងរៀបចំកម្មវិធីប្រគល់រង្វាន់សម្រាប់ «គម្រោងគំនិតផ្តួចផ្តើមរបស់យុវជន» ដែលទទួលជ័យលាភីក្នុងការប្រកួតប្រជែងសរសេរសំណើសម្រាប់អនុវត្តសកម្មភាពក្នុងសហគមន៍របស់ខ្លួន។ ក្នុងកម្មវិធីនេះក៏នឹងមានរៀបចំកិច្ចពិភាក្សាលើប្រធានបទ «ទស្សនៈរបស់យុវជនចំពោះស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ»។ នៅថ្ងៃដដែល នេះ ម.ស.ម.ក ក៏នឹងរៀបចំកម្មវិធីវិទ្យុកិច្ចពិភាក្សាផ្ទាល់ក្រោមប្រធានបទស្តីពី«បរិយាកាសនៃសេរីភាពសារព័ត៌មាន» នៅការិយាល័យរបស់ខ្លួនផងដែរ។
- នៅថ្ងៃទី០៦ ខែឧសភា ម.ស.ម.ក នឹងចេញផ្សាយនូវបណ្ណព័ត៌មានស្តីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា។
- នៅថ្ងៃទី០៧ និងថ្ងៃទី ០៨ ខែឧសភា ម.ស.ម.ក នឹងផ្សាយឡើងវិញនូវវីដេអូជីវចល ស្តីពីសេរីភាពសារព័ត៌មាន(កម្លាំងចិត្ត)និងបទចម្រៀងហ៊ីបហប់ស្តីពីសិទ្ធិទទួលព័ត៌មាន (ព័ត៌មានសេរី) នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។
- នៅថ្ងៃទី០៩ និងថ្ងៃទី១៣ ខែឧសភា ម.ស.ម.ក នឹងចេញផ្សាយនូវសម្រង់ខ្លឹមសារនៃកិច្ចពិភាក្សាវិទ្យុដែលរៀបចំឡើងថ្ងៃទី០៣ ខែឧសភា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក ហួន ផន អ្នកសម្របសម្រួលគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា នៃម.ស.ម.ក តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤ ៕

**<u>ចប់</u>**

**បណ្ណាធិការះ**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUSះ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និងជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។